ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ចចំណុះអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត **នាយកដ្ឋានសម្បទានដីសង្គមកិច្ច** ចំណុះអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ ១៨០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា ២.-**

នាយកដ្ឋានសម្បទានដីសង្គមកិច្ច មានតួនាទី និងភារកិច្ច ÷

- លើកផែនការសកម្មភាពការងារគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- សហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីថ្នាក់រាជធានី ខេត្ត ដើម្បីរកដីសម្រាប់គោលដៅសម្បទានដីសង្គមកិច្ច
- គាំទ្របច្ចេកទេសដល់ក្រុមការងារថ្នាក់ក្រោមជាតិដើម្បីរៀបចំផែនការបែងចែកនិងប្រើប្រាស់ដី
- លើកគោលការណ៍ត្រួតពិនិត្យ និងតាមដានការផ្តល់សម្បទានដីសង្គមកិច្ច
- ត្រួតពិនិត្យការរីកចម្រើនក្នុងការអនុវត្តការប្រើប្រាស់ដីសម្បទានសង្គមកិច្ច
- សហការជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូល និងចងក្រងទិន្នន័យការងារសម្បទានដីសង្គមកិច្ច
- លើកគោលការណ៍ត្រួតពិនិត្យ និងតាមដានការផ្តល់សម្បទានដីសង្គមកិច្ច និងកែប្រែគោលនយោបាយ និងបទប្បញ្ញត្តិនានាជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- លើកគោលការណ៍លុបចោលការសម្រេច ឬកែសម្រួលផែនការប្រើប្រាស់ និងបែងចែកដីនៅថ្នាក់រាជធានី ខេត្តជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- ធ្វើជាជំនួយការបច្ចេកទេសក្នុងការធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ច ការធ្វើសនិទានកម្មដីទំនេរជាមួយនឹងតម្រូវការដីសម្បទាន
- រៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដាក់ជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច
- ជំរុញតាមដាន វាយតម្លៃលើការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលការងារជូនគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ
- លើកផែនការថវិការបស់នាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកដ្ឋាន។

**មាត្រា ៣.-**

នាយកដ្ឋានសម្បទានដីសង្គមកិច្ច ដឹកនាំដោយប្រធាន ០១ រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ៤.-**

នាយកដ្ឋានសម្បទានដីសង្គមកិច្ច មានការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសម្បទានដីសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ